**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ២០៤ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ភារកិច្ចសារពើពន្ធចំពោះសហគ្រាសប្រកបអាជីវកម្ម ជាភ្នាក់ងារទេសចរណ៍ និងការីទេសចរណ៍

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៤៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម
- បានឃើញប្រកាសលេខ ០៩៨ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ស្តីពីពន្ធលើប្រាក់ចំណូល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

# សម្រេច

## ប្រការ ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងកំណត់នូវយន្តការពន្ធដារ ចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលប្រកបអាជីវកម្មជាភ្នាក់ងារទេសចរណ៍ និងការីទេសចរណ៍។

## ប្រការ ២.- គោលដៅ

ប្រកាសនេះ មានគោលដៅដាក់ចេញនូវវិធាននិងនីតិវិធីសម្រាប់អនុវត្តពន្ធលើប្រាក់ចំណូល ពន្ធកាត់ទុក និងអាករលើតម្លៃបន្ថែម ចំពោះភ្នាក់ងារទេសចរណ៍ និងការីទេសចរណ៍ដែលមានប្រតិបត្តិការអាជីវកម្មទាំងក្នុងនិងក្រៅព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៣.- វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលប្រកបអាជីវកម្មជាភ្នាក់ងារទេសចរណ៍ និងការីទេសចរណ៍។

## ប្រការ ៤.- និយមន័យ

សម្រាប់គោលដៅនៃប្រកាសនេះ÷

១- ពាក្យ "ភ្នាក់ងារទេសចរណ៍" សំដៅដល់ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលប្រកបអាជីវកម្មជាអ្នកជួយលក់ ឬកក់សេវាទេសចរណ៍ទាំងក្នុងនិងក្រៅព្រះរាជាណាចក្រកម្ពុជា ដែលក្នុងនោះមាន សំបុត្រមធ្យោបាយធ្វើដំណើរក្នុងនិងក្រៅប្រទេស សំបុត្រចូលទស្សនា សេវាស្នាក់នៅនិងអាហារក្នុងនិងក្រៅប្រទេស សេវាលិខិតឆ្លងដែន សេវាទិដ្ឋាការទូទៅ សេវាធានារ៉ាប់រង សេវាកែប្រែឬលុបចោលការកក់សេវាកម្សាន្តនានា និងសេវាទេសចរណ៍ផ្សេងៗទៀត ដោយរាប់បញ្ចូលផងដែរនូវការជួយលក់ខ្សែទស្សនកិច្ច ដែលបង្កើតឡើងដោយការីទេសចរណ៍ដើម្បីទទួលបាននូវកម្រៃជើងសាឬកម្រៃសេវា។

២- ពាក្យ "កម្រៃជើងសាឬកម្រៃសេវា" សំដៅដល់ កម្រៃ ឬចំនួនភាគរយនៃតម្លៃសេវាតាមកិច្ចព្រមព្រៀងដែលភ្នាក់ងារទេសចរណ៍ទទួលបានពីការផ្គត់ផ្គង់សេវាទេសចរណ៍។

៣- ពាក្យ "ការីទេសចរណ៍" សំដៅដល់ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលរៀបចំ និងលក់ខ្សែទស្សនកិច្ចព្រមទាំងប្រមូលផ្តុំសេវាទេសចរណ៍ផ្សេងៗ សម្រាប់លក់ដោយផ្ទាល់ ឬតាមរយៈភ្នាក់ងារទេសចរណ៍ ឬភាគីផ្សេងទៀតតាមកិច្ចសន្យា។ ការីទេសចរណ៍ ត្រូវបានបែងចែកជា ៣ ប្រភេទដូចខាងក្រោម÷

- ក- ការីទេសចរណ៍ដែលនាំភ្ញៀវក្នុងព្រះរាជាណាចក្រកម្ពុជា ធ្វើការកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា (Domestic Tour Operators)
- ខ- ការីទេសចរណ៍ដែលនាំភ្ញៀវពីក្រៅព្រះរាជាណាចក្រកម្ពុជា ចូលមកកម្សាន្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា (Inbound Tour Operators)
- គ- ការីទេសចរណ៍ដែលនាំភ្ញៀវពីក្នុងព្រះរាជាណាចក្រកម្ពុជា ទៅកម្សាន្តនៅក្រៅព្រះរាជាណាចក្រកម្ពុជា (Outbound Tour Operators)។

## ប្រការ ៥.~ លក្ខខណ្ឌដើម្បីទទួលស្គាល់ជាភ្នាក់ងារទេសចរណ៍

១- សម្រាប់គោលដៅនៃប្រកាសនេះ ដើម្បីទទួលបានលក្ខណសម្បត្តិជាភ្នាក់ងារទេសចរណ៍ អ្នកជាប់ពន្ធត្រូវបំពេញលក្ខខណ្ឌទាំង ៣ ដូចខាងក្រោម÷

ក- ចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស

ខ- មានអាជ្ញាប័ណ្ណភ្នាក់ងារទេសចរណ៍ពីក្រសួងទេសចរណ៍

គ- មានប្រតិបត្តិការអាជីវកម្មជាភ្នាក់ងារទេសចរណ៍ ដូចមានចែងក្នុងកថាខណ្ឌ១ នៃប្រការ៤ នៃប្រកាសនេះ។

២- ភ្នាក់ងារទេសចរណ៍ត្រូវមានឯកសារគាំទ្រដែលអាចត្រួតពិនិត្យបាន ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃការទទួលប្រាក់ឬទូទាត់ប្រាក់ជំនួសអ្នកទេសចរណ៍ឬការីទេសចរណ៍ឬអ្នកផ្គត់ផ្គង់សេវាទេសចរណ៍ ឬវិក្កយបត្រនិងរបាយការណ៍ទូទាត់ប្រចាំខែ (Billing Report) បោះពុម្ពចេញពីប្រព័ន្ធគ្រប់គ្រងវិក្កយបត្រនិងការទូទាត់ (Billing and Settlement Plan) ក្នុងករណីមានប្រតិបត្តិការជាមួយក្រុមហ៊ុនអាកាសចរណ៍ក្រៅស្រុកតាមរយៈសមាគមដឹកជញ្ជូនផ្លូវអាកាសអន្តរជាតិ (IATA)។

## ប្រការ ៦.~ មូលដ្ឋានគិតពន្ធអាករ

១- ភ្នាក់ងារទេសចរណ៍ ត្រូវកត់ត្រាចំណូលដុល ចំណាយចេញជំនួស និងត្រូវគណនាកម្រៃជើងសាឬកម្រៃសេវាក្នុងតារាងគណនាកម្រៃជើងសាឬកម្រៃសេវារបស់ភ្នាក់ងារទេសចរណ៍ ដូចមានចែងក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសនេះ។ កម្រៃជើងសាឬកម្រៃសេវា ដូចមានចែងក្នុងកថាខណ្ឌនេះ ត្រូវបានកំណត់ជាមូលដ្ឋានសម្រាប់គិតអាករលើតម្លៃបន្ថែមតាមអត្រា១០% និងប្រាក់រំដោះពន្ធលើប្រាក់ចំណូលតាមអត្រា១%។

២- ការីទេសចរណ៍ត្រូវកំណត់មូលដ្ឋានគណនាពន្ធអាករដូចខាងក្រោម÷

ក- ការីទេសចរណ៍ដែលនាំភ្ញៀវក្នុងព្រះរាជាណាចក្រកម្ពុជា ធ្វើការកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវកត់ត្រាចំណូលដុល (មិនរួមបញ្ចូលអតប.) សម្រាប់គិតអាករលើតម្លៃបន្ថែមតាមអត្រា១០% ប្រាក់រំដោះពន្ធលើប្រាក់ចំណូលតាមអត្រា១% និងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។

ខ- ការីទេសចរណ៍ដែលនាំភ្ញៀវពីក្រៅព្រះរាជាណាចក្រកម្ពុជា ចូលមកកម្សាន្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវកត់ត្រាចំណូលដុល (មិនរួមបញ្ចូលអតប.) វៀរលែងតែថ្លៃសំបុត្រដឹកអ្នកដំណើរអន្តរជាតិ សម្រាប់គិតអាករលើតម្លៃបន្ថែមតាមអត្រា១០% ប្រាក់រំដោះពន្ធលើប្រាក់ចំណូលតាមអត្រា១% និងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។

គ- ការីទេសចរណ៍ដែលនាំភ្ញៀវពីក្នុងព្រះរាជាណាចក្រកម្ពុជា ទៅកម្សាន្តនៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវកត់ត្រាចំណូលដុល (មិនរួមបញ្ចូលអតប.) វៀរលែងតែថ្លៃសំបុត្រដឹកអ្នកដំណើរអន្តរជាតិ សម្រាប់គិតអាករលើតម្លៃបន្ថែមតាមអត្រា០% ប្រាក់រំដោះពន្ធលើប្រាក់ចំណូលតាមអត្រា១% និងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។ ចំពោះចំណាយសម្រាប់ខ្សែទស្សនកិច្ចនៅក្រៅព្រះរាជាណាចក្រកម្ពុជា មិនមែនជាកម្មវត្ថុនៃពន្ធកាត់ទុកទេ។

ឃ- ការីទេសចរណ៍ដែលរៀបចំ និងលក់ខ្សែទស្សនកិច្ចចម្រុះទាំងក្នុងនិងក្រៅព្រះរាជាណាចក្រកម្ពុជា (Mixed-Package Tour) ត្រូវគណនាមូលដ្ឋានដូចខាងក្រោម÷

- យកចំណូលសរុបរួមទាំងអតប. ពីខ្សែទស្សនកិច្ច គុណនឹងសមាមាត្រនៃចំនួនថ្ងៃទស្សនកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាធៀបនឹងចំនួនថ្ងៃទស្សនកិច្ចសរុប ហើយចែកនឹង ១,១ ធ្វើជាមូលដ្ឋានគិតអាករលើតម្លៃបន្ថែមតាមអត្រា១០%
- យកចំណូលដុល (មិនរួមបញ្ចូលអតប.) វៀរលែងតែថ្លៃសំបុត្រដឹកអ្នកដំណើរអន្តរជាតិ ធ្វើជាមូលដ្ឋានគិតប្រាក់រំដោះពន្ធលើប្រាក់ចំណូលតាមអត្រា១% និងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។

អ្នកជាប់ពន្ធអាចកាត់កងចំណាយទាក់ទិននឹងប្រតិបត្តិការដូចមានចែងក្នុងវាក្យខណ្ឌនេះ ស្របតាមលក្ខខណ្ឌនៃចំណាយដែលអាចកាត់កងបាន ដូចមានចែងក្នុងបទប្បញ្ញត្តិស្ដីពីពន្ធលើប្រាក់ចំណូល។ ចំណាយសម្រាប់ខ្សែទស្សនកិច្ចក្រៅព្រះរាជាណាចក្រកម្ពុជា មិនមែនជាកម្មវត្ថុនៃពន្ធកាត់ទុកទេ។

៣- ភ្នាក់ងារទេសចរណ៍ និងការីទេសចរណ៍ ត្រូវបានអនុញ្ញាតឥណទានអាករលើធាតុចូល ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា២៩ ដល់មាត្រា៤១ នៃអនុក្រឹត្យស្ដីពីអាករលើតម្លៃបន្ថែម។

## ប្រការ ៧.- កាតព្វកិច្ចកាន់បញ្ជីគណនេយ្យនិងដាក់លិខិតប្រកាសបង់ពន្ធអាករ

ភ្នាក់ងារទេសចរណ៍ និងការីទេសចរណ៍ ត្រូវមានកាតព្វកិច្ចកាន់បញ្ជីគណនេយ្យឱ្យបានត្រឹមត្រូវ និងដាក់លិខិតប្រកាសបង់ពន្ធអាករនានា ស្របតាមច្បាប់និងបទប្បញ្ញត្តិស្ដីពីពន្ធដារជាធរមាន។

## ប្រការ ៨.- ការអនុវត្តប្រកាស

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក និងអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់សហគ្រាសនិងស្ថាប័នពាក់ព័ន្ធនានា ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែជេស្ឋ ឆ្នាំជូត ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ ÷ តារាងគណនាកម្រៃជើងសា / កម្រៃសេវារបស់ភ្នាក់ងារទេសចរណ៍

ឈ្មោះក្រុមហ៊ុន ........................................

អាសយដ្ឋាន ........................................................

ទូរសព្ទ÷ ........................................

លេខអត្តសញ្ញាណកម្ម អ.ត.ប L001-10XXXXXXX

សកម្មភាពអាជីវកម្មចម្បង÷ ភ្នាក់ងារទេសចរណ៍

| កាលបរិច្ឆេទ | លេខវិក្កយបត្រ | អ្នកទិញ | លេខ អតប | សេចក្តីបរិយាយ | បរិមាណ | ចំណូលដុល | ចំណាយចេញជួស | កម្រៃជើងសា / កម្រៃសេវា |
|---|---|---|---|---|---|---|---|---|
| Date | Invoice No. | Clients | VATIN | Description | Qty | Gross Revenue | Reimbursement | Commission |
| 1-Jan-20 | 00001 | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |